វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
Cambodian Rubber Research Institute

# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០២០



# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០២០

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ថ្ងៃ ព្រហស្បតិ៍ ២រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

# អារម្ភកថា

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា(**វ.ស.ក.ក**)មានកិត្តិយសក្នុងការបង្ហាញជូននូវរបាយកាណ៍សកម្មភាពការងារស្រាវជ្រាវប្រចាំឆ្នាំ២០២០ ដើម្បីជាព័ត៌មានដល់អ្នកពាក់ព័ន្ធទៅនឹងការងារស្រាវជ្រាវ និងផលិតកម្មដំណាំកៅស៊ូ។ របាយការណ៍នេះបង្ហាញជូននូវសកម្មភាពការងារស្រាវជ្រាវ និងសមិទ្ធផលចម្បងៗរបស់ការិយាល័យមានដូចជា (១)ការិយាល័យបង្កាត់ពូជ (២)ការិយាល័យដាំដុះនិងការពារ (៣)ការិយាល័យសរីរវិទ្យានិងអាជីវកម្ម (៤)មន្ទីរពិសោធន៍ជាតិយថាប្រភេទ ព្រមទាំងការិយាល័យពាក់ព័ន្ធមួយចំនួនទៀតក្រោមឱវាទ **វ.ស.ក.ក**។

លទ្ធផលការងារដែលបង្ហាញជូនក្នុងរបាយការណ៍សកម្មភាពនេះ សម្រេចបានដោយសារ កិច្ចខិតខំប្រឹងប្រែងអនុវត្តការងារប្រកបដោយកិច្ចសហការយ៉ាងជិតស្និទ្ធរវាងមន្ត្រីរាជការ និយោជិត និងថ្នាក់ដឹកនាំ **វ.ស.ក.ក** ទាំងអស់នៅក្នុងការពិសោធន៍ ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា និងការចូលរួមពីប្រតិបត្តិករកៅស៊ូពាក់ព័ន្ធទាំងអស់ ហើយនិងបណ្តាដៃគូអន្តរជាតិផ្សេងទៀតមានដូចជា: មជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវអន្តរជាតិដើម្បីអភិវឌ្ឍកសិកម្ម (CIRAD), ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB), ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD), បណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន(CATAS), វេទិកាដៃគូស្រាវជ្រាវកៅស៊ូ(HRPP) ព្រមជាមួយគ្នានោះ ដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាភិបាល និងជាពិសេសកិច្ចគាំទ្រនិងតម្រង់ទិសពីស្ថាប័នអាណាព្យាបាលរួមមាន៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ ដើម្បីជំរុញការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជាប្រកបដោយវឌ្ឍនភាព និងចីរភាព។

ខ្ញុំសង្ឃឹមថា ប្រតិបត្តិករកៅស៊ូ និងអ្នកពាក់ព័ន្ធទាំងឡាយក្នុងវិស័យកៅស៊ូនឹងទទួលបាននូវព័ត៌មានផ្សេងៗពីការពិសោធស្រាវជ្រាវដំណាំកៅស៊ូតាមរយៈរបាយការណ៍នេះ ព្រមទាំងចូលរួមសហការ ផ្តល់នូវមតិគាំទ្រ កែលម្អ និងតម្រង់ទិសការងារពិសោធស្រាវជ្រាវ ហើយនិងការរៀបចំនូវរបាយការណ៍សកម្មភាពនេះឲ្យមានលក្ខណៈកាន់តែប្រសើរឡើង។

ថ្ងៃ ព្រហស្បតិ៍ ២រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

**នាយក**
**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

**លិម ខាន់ទីវ៉ា**

# មាតិកា

ទំព័រ


អារម្ភកថា ..... ii
១. សេចក្តីផ្តើម ..... 1
២. អង្គការលេខ និងស្ថានភាពបុគ្គលិក ..... 2
២.១. អង្គការលេខ ..... 2
២.២. ស្ថានភាពបុគ្គលិក ..... 3
៣. សមិទ្ធផល និងលទ្ធផលតាមផ្នែក ..... 4
៣.១. សមិទ្ធផល ..... 4
៣.១.១. ផ្នែកក្សេត្រសាស្ត្រ ..... 4
៣.១.២. ផ្នែកមន្ទីរពិសោធន៍យថាប្រភេទ ..... 5
៣.១.៣. ការបណ្តុះបណ្តាល ..... 5
៣.១.៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ ..... 6
៣.២. លទ្ធផលតាមផ្នែក ..... 8
៣.២.១. ការិយាល័យបង្កាត់ពូជ ..... 8
៣.២.២. ការិយាល័យដាំដុះ និងការពារ ..... 10
៣.២.៣. ការិយាល័យសរីរវិទ្យា និងអាជីវកម្ម ..... 13
៣.២.៤. មន្ទីរពិសោធន៍ជាតិយថាប្រភេទ ..... 15
៣.២.៥. ស្ថានីយ៍អនុវត្ត ..... 18
៣.៣. ការអនុវត្តថវិកាកម្មវិធី ..... 19
៣.៣.១. ចង្កោមសកម្មភាពទី១ ពង្រឹងការពិសោធន៍ និងស្រាវជ្រាវដំណាំកៅស៊ូ ..... 19
៣.៣.២. ចង្កោមសកម្មភាពទី២ ពង្រឹងគុណភាពផលិតផលកៅស៊ូកម្ពុជាស្របទៅតាមស្តង់ដារអន្តរជាតិ ..... 19
៣.៣.៣. ចង្កោមសកម្មភាពទី៣ ពង្រឹងយន្តការទ្រទ្រង់ដល់ការស្រាវជ្រាវ និងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ..... 19
៤. ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ..... 20
៥. ទិសដៅការងារឆ្នាំ២០២១ និងសន្និដ្ឋាន ..... 21
៥.១. ទិសដៅការងារឆ្នាំ២០២១ ..... 21
៥.២. សេចក្តីសន្និដ្ឋាន ..... 21
៦. ការប្រជុំ និងសិក្ខាសាលា ..... 22
៧. រូបភាពសកម្មភាពផ្សេងទៀត ..... 30

## ១. សេចក្តីផ្តើម

កៅស៊ូធម្មជាតិជាដំណាំសេដ្ឋកិច្ច និងយុទ្ធសាស្ត្រយ៉ាងសំខាន់ ដែលផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនលើសលប់ដល់អ្នកដាំ ផ្តល់ជាចំណូលដល់សេដ្ឋកិច្ចជាតិនិងសង្គម ព្រមទាំងបរិស្ថាន។ ជាការឆ្លើយតបទៅនឹងគោលដៅយុទ្ធសាស្ត្រលើកស្ទួយវិស័យកសិកម្ម នៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលអាណត្តិទី៦ ផែនការសកម្មភាពជាតិស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យនៅកម្ពុជា២០១៦-២០២៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ក្រសួងកសិកម្មបានលើកឡើងនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យ កសិកម្ម ២០១៩-២០២៣ ទិសដៅគោលនយោបាយរួមសំដៅ ជំរុញកំណើនក្នុងវិស័យកសិកម្មឲ្យបានក្នុងរង្វង់៤%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកំពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព។ ក្នុងបរិបទនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចដាក់ឲ្យអនុវត្តនូវកម្មវិធីចំនួន៥ ក្នុងនោះ **វ.ស.ក.ក** ស្ថិតនៅក្នុងកម្មវិធី ទី១ គឺ៖ បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច។ **វ.ស.ក.ក** ជាអង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតក្រោមអាណាព្យាបាលចំនួនពីរគឺ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលផ្នែក ហិរញ្ញវត្ថុ ព្រមជាមួយនឹងការដឹកនាំតម្រង់ទិសពីអង្គការកំពូលមួយគឺ ក្រុមប្រឹក្សាភិបាល។ **វ.ស.ក.ក** ត្រូវបានប្រគល់ភារកិច្ចឲ្យអនុវត្តការងារនៅក្នុងកម្មវិធីទី១ និងអនុកម្មវិធីទី៦ ស្តីអំពី៖ **«លើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ »** ដែលក្នុងនោះមានចង្កោមសកម្មភាពចំនួន៣ គឺ៖ ***១.៦.១.*** **ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ និងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូដើម្បីបង្កើនផលិតភាពកៅស៊ូ ១.៦.២៖ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាពនិងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ ១.៦.៣ ៖ទទួលធ្វើសវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យស្គាល់ជាផ្លូវការនិងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ។**

របាយការណ៍សកម្មភាពនេះគឺជាសមិទ្ធផលសំខាន់ៗ របស់ **វ.ស.ក.ក** ឆ្លើយតបទៅនឹងគោលនយាបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្ម ២០១៩-២០២៣ ហើយនិងផែនការរយៈពេលខ្លី មធ្យម និងវែងរបស់ **វ.ស.ក.ក** ទៅតាមសូចនាករដែលបានគ្រោងទុកនៅក្នុងកម្មវិធី និងអនុកម្មវិធីដែលបានកំណត់ សំដៅរួមចំណែកក្នុងការបង្កើនផលិតភាពនិងតម្លៃបន្ថែមទៀត បង្កើនប្រភពចំណូលដល់កសិករ និងសេដ្ឋកិច្ចជាតិ ហើយនិងការអភិវឌ្ឍដំណាំកៅស៊ូប្រកបដោយនិរន្តរភាព។

# ២. អង្គការលេខ និងស្ថានភាពបុគ្គលិក

## ២.១. អង្គការលេខ




**យោង៖** -អនុក្រឹត្យលេខ៦៩អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

-អនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមមាត្រា៥ ចំណុច៥.១ នៃអនុក្រឹត្យលេខ៦៩អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧

វ.ស.ក.ក ជាអង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមរយៈអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ និងកែសម្រួលឡើងវិញដោយអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០១៩ ដោយបានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាលជាលើកទី២ ក្នុងនោះបានចង្អុលបង្ហាញអំពីភារកិច្ច ដែលមានខ្លឹមសារថា៖ វ.ស.ក.ក មានភារកិច្ចដឹកនាំ និងសម្រេចរាល់សកម្មភាពស្រាវជ្រាវ និងការពិសោធន៍សំដៅជម្រុញការអភិវឌ្ឍលើគ្រប់ផ្នែក នៃដំណាំកៅស៊ូទូទៅ និងចូលរួមរាល់សកម្មភាពនៃការជម្រុញ ផ្នែកបច្ចេកទេសសុវឌ្ឍកម្មនៃគុណភាពកៅស៊ូ និងតម្លៃផលិតកម្ម។ ក្នុងការបង្កើនផលិតភាពកៅស៊ូ វ.ស.ក.ក បានយកចិត្តទុកដាក់ដល់ការស្រាវជ្រាវបង្កាត់ពូជកៅស៊ូសំដៅបង្កើតនូវក្លូនកៅស៊ូកម្ពុជាដែលមានសក្តានុពលបន្សាំនឹងបម្រែបម្រួលអាកាសធាតុ មានទិន្នផលខ្ពស់ និងលូតលាស់ល្អសមស្របនឹងលក្ខណ្ឌបរិស្ថាននៃប្រទេសកម្ពុជា ការស្រាវជ្រាវសរីរវិទ្យានិងអាជីវកម្ម និងការស្រាវជ្រាវអំពីការដាំដុះនិងការពារ។ ក្នុងឆ្នាំ ២០២០នេះ វ.ស.ក.ក បានអនុវត្តនិងបន្តការងារស្រាវជ្រាវ ហើយនិងតាមដានទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ ដែលជាសរុបមាន៦២ពិសោធន៍។ ទន្ទឹមគ្នានឹងការស្រាវជ្រាវ វ.ស.ក.ក បានរួមចំណែកយ៉ាងធំធេងនៅក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដោយការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ព្រមជាមួយគ្នានោះក៏បានបណ្តុះបណ្តាលនូវធនធានមនុស្ស តាមរយៈការបង្ហាត់បង្រៀននិស្សិត នៅតាមគ្រឹះស្ថានសិក្សា និងការសម្របសម្រួលឱ្យនិស្សិតធ្វើទស្សនកិច្ចសិក្សា ចម្ការពិសោធន៍ និងការដឹកនាំសារណា បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់និស្សិត មកពីគ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួនដើម្បីបន្តវេនក្នុងការអភិវឌ្ឍដំណាំកៅស៊ូនាអនាគត។ នៅក្នុងអនុក្រឹត្យ វ.ស.ក.ក មានកាតព្វកិច្ចចំនួន៦ ចំណុចសំខាន់ ដែលត្រូវបានរំលេចឡើង សំដៅលើការអនុវត្តឲ្យបានសម្រេចឆ្លើយតបទៅនឹងភារកិច្ចខាងលើ។

ឆ្លើយតបទៅនឹងការអនុវត្តភារកិច្ចខាងលើ អង្គការលេខមួយត្រូវបានរៀបចំឡើង ដើម្បីចង្អុលបង្ហាញអំពីកាតព្វកិច្ចរបស់បណ្តាការិយាល័យ និងបណ្តាអង្គភាពចំណុះរបស់ វ.ស.ក.ក តាមរយៈប្រកាសលេខ៥៧៦ ប្រក.កសក.បុ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣។ យោងសេចក្តីប្រកាសនេះ វ.ស.ក.ក មានការិយាល័យ និងអង្គភាពចំណុះចំនួន៧ រួមមាន៖

១- ការិយាល័យ រដ្ឋបាល និងបុគ្គលិក

២- ការិយាល័យ ផែនការ និងគណនេយ្យ

៣- ការិយាល័យ បង្កាត់ពូជ

៤- ការិយាល័យ ដាំដុះ និងការពារ

៥- ការិយាល័យ សរីរវិទ្យា និងអាជីវកម្ម

៦- មន្ទីរពិសោធន៍ជាតិយថាប្រភេទ មានថ្នាក់ស្មើការិយាល័យ

៧- ស្ថានីយ៍អនុវត្ត មានថ្នាក់ស្មើការិយាល័យ

## ២.២ ស្ថានភាពបុគ្គលិក

មន្ត្រី វ.ស.ក.ក ក្នុងក្របខ័ណ្ឌមុខងារសាធារណៈបច្ចុប្បន្នមានចំនួនសរុប៤៣នាក់ ក្នុងនោះមានស្ត្រី១១នាក់ និងកម្មករកិច្ចសន្យាផ្នែកចៀរជ័រ ដាំដុះ រោងចក្រ គ្រូបង្រៀន និងការងារបម្រើសេវាផ្សេងៗទៀត ដែលមានចំនួនសរុប២០៨នាក់។ មន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈទាំង៤៣នាក់មានកម្រិតសញ្ញាបត្រដូចខាងក្រោម៖

| | |
|---|---|
| + បណ្ឌិត | ០១នាក់ |
| + បរិញ្ញាបត្រជាន់ខ្ពស់ | ០៦នាក់ |
| + បរិញ្ញាបត្រ | ៣០នាក់ |
| + បរិញ្ញាបត្ររង | ០៣នាក់ |
| + បឋមឯកទេស | ០៣នាក់ |

# ៣. សមិទ្ធផល និងលទ្ធផលតាមផ្នែក

## ៣.១. សមិទ្ធផល

ការបំពេញភារកិច្ចក្នុងឆ្នាំ២០២០ ក៏ដូចបណ្ដាឆ្នាំមុនៗកន្លងមកដែរ **វ.ស.ក.ក** បានខិតខំបន្តអនុវត្តការងារពិសោធន៍ និងស្រាវជ្រាវឆ្លើយតបទៅនឹងបរិបទនៃការអភិវឌ្ឍដូចមានចែងនៅក្នុងអនុក្រឹត្យស្ដីពីការបង្កើត **វ.ស.ក.ក** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

### ៣.១.១. ផ្នែកក្សេត្រសាស្ត្រ

- ស្រង់ បញ្ចូលនិងវិភាគទិន្នន័យគ្រប់ចម្ការពិសោធន៍ចំនួន៦២ ក្នុងបរិវេណស្ថានីយអនុវត្ត និងនៅតាមបណ្ដាក្រុមហ៊ុន (ចម្ការពិសោធន៍លើគ្រប់ផ្នែកពាក់ព័ន្ធនឹងវិធីសាស្ត្រដាំដុះនិងការពារ ការធ្វើពិពិធកម្មដំណាំចន្លោះរង ពិពិធកម្មក្លូននិងប្រៀបធៀបក្លូន ហើយនិងពិសោធន៍សរីរសាស្ត្រនិងប្រមូលផលទឹកជ័រ)
- ការថែទាំដំណាំគ្របដីចំនួន៣ប្រភេទ មាន Stylosanthes guiannsis , Mucuna aterrinum , Pueraria phaseoloides
- ធ្វើតេស្តចៀរជ័រវាយតម្លៃទិន្នផលចម្ការពិសោធន៍ជម្រើសពូជបឋម(SET)
- រៀបចំថ្នាលបណ្ដុះកូនកៅស៊ូថ្មី និងអភិវឌ្ឍរុក្ខសម្ភារដាំដុះកៅស៊ូ
- ថែទាំច្បារពូជកៅស៊ូនិងច្បារបង្កាត់ពូជសម្រាប់បម្រើដល់ការពិសោធន៍ស្រាវជ្រាវ
- អភិវឌ្ឍធនធានសេនេទិចកៅស៊ូ
- ចុះអង្កេតការជ្រុះស្លឹក និងចេញផ្ការនៅច្បារបង្កាត់ពូជលើក្លូនកៅស៊ូចំនួន១៦
- ដាំកូនកៅស៊ូបំបៅដោយក្លូនទទួលពីក្រុមហ៊ុន SOCFIN-KCD និងពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូនៃបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន(CATAS) នៅក្នុងច្បារពូជ Collection សរុបបានចំនួន ១៧ ក្លូន
- ចុះត្រួតពិនិត្យទីតាំងដើម្បីរៀបចំច្បារពូជដល់កសិករ នៅឃុំកំពាន់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានចំនួន ០២គ្រួសារ
- ចុះអង្កេតពីការប្រើប្រាស់ក្លូនកៅស៊ូនៅខេត្តមណ្ឌលគិរី ក្រចេះ និងខេត្តកំពង់ធំ
- ធ្វើការវិភាគរកស្ដង់ដាសរីរសាស្ត្រទឹកជ័រលើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (RSH)
- យកសំណាកនិងវិភាគសរីរទឹកជ័រ( LD) នៅចម្ការពិសោធន៍នានាក្នុងនិងក្រៅស្ថានីយ បានចំនួន២៩ចម្ការពិសោធន៍ ស្មើនឹង ១២៨០សំណាក

### ៣.១.២. ផ្នែកមន្ទីរពិសោធន៍យថាប្រភេទ

- ធ្វើតេស្តវិភាគសំណាកយថាប្រភេទកៅស៊ូសម្រាប់វាយតម្លៃគុណភាពកែច្នៃរបស់រោងចក្រ CSR និងកៅស៊ូប្រភេទ RSS
- ធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក បានចំនួន៣០២សំណាក
- ធ្វើតេស្ត និងបានចេញលទ្ធផលតេស្តជូនរោងចក្រកៅស៊ូសន្លឹក របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- ធ្វើតេស្ត និងបានចេញលទ្ធផលតេស្តជូនក្រុមហ៊ុន សុកហ្វីន កាសេដេ ខូ, អិលធីឌី (SOCFIN KCD CO., LTD) ភូមិប៊ូស្រា ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី បានចំនួន៦០សំណាក
- ផ្សព្វផ្សាយសារាចរណែនាំស្តីពី ការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ បានចំនួន១០រោងចក្រ
- ជូនដំណឹង ស្តីពី“ សំណើសុំចូលរួមធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក)Parallel Tests) សម្រាប់ឆ្នាំ២០២០” ជូនដល់បណ្តាក្រុមហ៊ុន រោងចក្របានចំនួន១១ និងមន្ទីរពិសោធន៍មូលដ្ឋាន ចំនួន ៥ ដែលបានចុះបញ្ជិកាជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃមន្ទីរពិសោធន៍មូលដ្ឋាន និងរោងចក្រកែច្នៃកៅស៊ូ CSR នៃបណ្តាក្រុមហ៊ុន
- រៀបចំពិសោធន៍លើការប្រើប្រាស់អាស៊ីត៣ប្រភេទខុសគ្នា) អាស៊ីតស៊ុលផួរិក, អាស៊ីតហ្វ័រមិក និងម្សៅអាស៊ីត) លើទឹកជ័រកៅស៊ូក្លូន GT1 និង PB217 និងបានទទួលលទ្ធផលបឋមអំពីការ ប្រើសាជូរខៀវបង្កកទឹកជ័រ
- អនុវត្តការងារមន្ទីរពិសោធន៍ជាតិយថាប្រភេទតាមប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025: 2017
- បានរៀបចំឯកសារដើម្បីស្នើសុំស្តង់ដារ ISO/IEC 17025: 2017
- ក្នុងឆ្នាំ២០២០ បានចុះបញ្ជិកាំរោងចក្រកែច្នៃកៅស៊ូ CSR ចំនួន៤រោងចក្រ និងមន្ទីរពិសោធន៍ចំនួន១ (បច្ចុប្បន្នក្រុមហ៊ុន/រោងចក្រកែច្នៃកៅស៊ូដែលបានចុះបញ្ជិកាជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូមានចំនួន ១៣រោងចក្រ និងមន្ទីរពិសោធន៍ចំនួន៦)

### ៣.១.៣. ការបណ្តុះបណ្តាល

❖ **ការបណ្តុះបណ្តាលផ្ទៃក្នុង**

ក្នុងការពង្រឹងគុណភាព និងសមត្ថភាពធនធានមនុស្សក្នុងការងារស្រាវជ្រាវ នៅឆ្នាំ២០២០នេះ **វ.ស.ក.ក** បាន បញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ ក្នុងនោះរួមមាន៖

➢ *សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលក្នុងប្រទេស:*

- មន្ត្រីរាជការចំនួន០៤នាក់ ចូលរួមវគ្គបណ្តុះបណ្តាលចំនួន២វគ្គគឺ: ១.វគ្គបណ្តុះបណ្តាលស្តីពីការពិពណ៌នាមុខតំណែង វិជ្ជាជីវ និងលក្ខណ្ឌការងារ នៅក្រសួងកសិកម្ម។ ២.វគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីអនុវត្តថវិកាសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅសណ្ឋាគារភ្នំពេញ
- មន្ត្រីរាជការចំនួន០៦នាក់ ចូលរួមសិក្ខាសាលាចំនួន៣គឺ: ១.សិក្ខាសាលាស្តីពីការបូកសរុបការអនុវត្តចំណូលចំណាយថវិកាឆ្នាំ២០១៩ និងទិសដៅឆ្នាំ២០១៩-២០២៣ របស់រដ្ឋបាលកណ្តាលនិងមន្ទីរកសិកម្មខេត្ត នៅទីរួមខេត្តកែប។ ២.សិក្ខាសាលាស្តីពីយន្តការនិងនីតិវិធីសម្រាប់រៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំ រំកិល ២០២១- ២០២៣ នៅខេត្តតាកែវ។ ៣.សិក្ខាសាលាស្តីពីការរៀបចំផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ នៅខេត្តកំពង់ចាម។

❖ ការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ

ក្នុងការរួមចំណែកដល់ការអភិវឌ្ឍដំណាំកៅស៊ូ ទន្ទឹមគ្នានឹងការអភិវឌ្ឍធនធានមនុស្ស **វ.ស.ក.ក** បានយកចិត្តទុកដាក់ដល់ការបណ្តុះបណ្តាល ផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងផ្សេងៗទៅដល់ប្រតិបត្តិករកៅស៊ូ សំដៅផ្តល់នូវចំណេះដឹង ចំណេះធ្វើ ហើយនិងបង្កើននូវភាពជឿជាក់និងឱកាសជោគជ័យ នៅក្នុងការវិនិយោគលើផលិតកម្មដំណាំកៅស៊ូ។ ការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ត្រូវបានអនុវត្តលើគ្រប់មុខជំនាញទៅតាមវិធីសាស្ត្រផ្សេងៗ ដែលអាចធ្វើទៅបានមានដូចជា៖

- ការបើកវគ្គបណ្តុះបណ្តាល និងការបង្ហាញនៅនឹងកន្លែងលើមុខជំនាញផ្សេងៗ ពាក់ព័ន្ធនឹងដំណាំកៅស៊ូ
- ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានសិក្សា ដូចជា៖ បណ្តុះបណ្តាលនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម ជំនាញវិទ្យាសាស្ត្រដំណាំកៅស៊ូ លើមុខវិជ្ជា ជំងឺនិងកក្កាចង្រៃលើដំណាំកៅស៊ូ និងការប្រមូលនិងថែរក្សាទឹកជ័រ។ ការបណ្តុះបណ្តាលនិស្សិតវិទ្យាស្ថានជាតិកសិកម្មកំពង់ចាមថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម ជំនាញវិទ្យាសាស្ត្រ ដំណាំកៅស៊ូ លើមុខវិជ្ជា បច្ចេកទេសដាំដុះកៅស៊ូ ការវិភាគសរីរទឹកជ័រ និងបច្ចេកទេសចៀរជ័រ
- ការទទួលកសិករ និងសិស្សនិស្សិតធ្វើទស្សនកិច្ចសិក្សា កម្មសិក្សា
- បណ្តុះបណ្តាលកសិករអំពីបច្ចេកទេសប្រមូលផលទឹកជ័រនៅខេត្តត្បូងឃ្មុំ
- ការទទួលនិស្សិតធ្វើសារណាបទ និងដឹកនាំសារណាបទមួយចំនួនដូចជា៖ ទទួលនិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មជំនាញវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំនួន០២នាក់ និងវិទ្យាស្ថានជាតិកសិកម្មព្រែកលាប ចំនួន ១នាក់ ដើម្បីសរសេរសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ
- ការរៀបចំសិក្ខាសាលា៖ វិទ្យាស្ថានបានសហការជាមួយដៃគូឯកជនរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការផ្ទេរបច្ចេកវិទ្យាកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ និងកៅស៊ូគ្រួសារ" ដែលមានអ្នកចូលរួមចំនួន១២៤នាក់ នៅខេត្តកំពង់ចាម ពីថ្ងៃទី៣០ ខែកញ្ញា ដល់ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ ហើយថ្នាក់ដឹកនាំនិងមន្ត្រីជំនាញបានធ្វើបទបង្ហាញបច្ចេកទេសចំនួន៩គឺ៖

    ១.សរីរវិទ្យានិងការវិភាគទឹកជ័រ

    ២.ការជ្រើសរើសពូជកៅស៊ូយកទៅដាំដុះ ដើម្បីទទួលបានទិន្នផលខ្ពស់

    ៣.ការប្រើប្រាស់ជីលើកៅស៊ូកំពុងផ្តល់ផល

    ៤.ជំងឺស្លឹកកៅស៊ូ *Pestalotiopsis*

    ៥.ការបើកមុខចៀរដំបូង

    ៦.បច្ចេកទេសប្រមូលផលទឹកជ័រកៅស៊ូ និងចង្វាក់នៃការលាបថ្នាំរំញោចបង្កើនទិន្នផល

    ៧.បច្ចេកទេសគន្លឹះកែច្នៃកៅស៊ូធម្មជាតិ កៅស៊ូដុំ (TSR) និងកៅស៊ូសន្លឹក (RSS)

    ៨.អត្ថប្រយោជន៍និងនីតិវិធីក្នុងការចុះបញ្ជិការោងចក្រ និងមន្ទីរពិសោធន៍មូលដ្ឋាន

    ៩.លទ្ធផលបឋមអំពីការប្រើសាជូរខៀវបង្កកទឹកជ័រ។

### ៣.១.៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្នុងទិសដៅពង្រឹងការងារស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាកៅស៊ូដល់ប្រតិបត្តិករឲ្យកាន់តែមានប្រសិទ្ធភាព ហើយនិងការទាញយកអត្ថប្រយោជន៍បច្ចេកវិទ្យាកៅស៊ូ ពីបណ្តាប្រទេសអភិវឌ្ឍនានា **វ.ស.ក.ក** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាវិទ្យាស្ថាន និងអង្គការអន្តរជាតិជាច្រើនរួមមាន៖

❖ ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB)

គឺជាបណ្តាញស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដែលប្រមូលផ្តុំរាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិស្ទើរតែគ្រប់

ប្រទេសផលិតកៅស៊ូធម្មជាតិទាំងអស់ដែលមាន៩៥% នៃបរិមាណផលិតផលកៅស៊ូធម្មជាតិនៃពិភពលោក។ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយបណ្តាប្រទេសជាសមាជិក IRRDB និងការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូកម្ពុជា។ នៅឆ្នាំ២០១៦ ប្រទេស**កម្ពុជា** បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិស្តីអំពី « **និរន្តរភាពនៃឧស្សាហកម្មកៅស៊ូធម្មជាតិ បញ្ហា ការប្រឈម និងកាលានុវត្តភាព** » ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ដោយមានគណៈប្រតិភូពីបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិចំនួន១៦ និងប្រទេសជាដៃគូចំនួន០២ផ្សេងទៀត ព្រមជាមួយនិងភ្ញៀវចូលរួមសរុបចំនួន៣៣០ នាក់។ នៅឆ្នាំ២០១៧ ***វ.ស.ក.ក*** បានសហការជាមួយ IRRDB ក្នុងការរៀបចំសិក្ខាសាលាអន្តរជាតិ IRRDB-Workshop ស្តីអំពី ***"ការផ្ទេរបច្ចេកវិទ្យាដល់ផលិតករកៅស៊ូ និងកៅស៊ូគ្រួសារ"*** ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃ ទី១២-១៣ ខែកក្កដា ឆ្នាំ២០១៧ នៅសណ្ឋាគារ សាន់វ៉េ រាជធានីភ្នំពេញ ដោយមានភ្ញៀវពីបណ្តាសមាជិក IRRDB ចំនួន០៩ ប្រទេសគឺៈ **កម្ពុជា ចិន ថៃ បារាំង ម៉ាឡេស៊ី ស្រីលង្កា ហ្វីលីពីន វៀតណាម និងអូស្ត្រាលី** អញ្ជើញចូលរួមសរុបចំនួន១៦៩នាក់។

### ❖ កិច្ចសហប្រតិបត្តិការជាមួយ CIRAD

ក្នុងការពង្រឹងសមត្ថភាពនិងបង្កើននូវប្រសិទ្ធិភាពសិក្សាស្រាវជ្រាវអំពី បច្ចេកទេសនិងវិទ្យាសាស្ត្រដំណាំកៅស៊ូ ***វ.ស.ក.ក*** បានធ្វើសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្ម សម្រាប់ការអភិវឌ្ឍន៍ (CIRAD) នៃប្រទេសបារាំង ដោយបានចុះអនុស្សរណៈនៃការយោគយល់គ្នាមួយកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ នៅ ***វ.ស.ក.ក***។ នៅឆ្នាំ២០២០នេះ ចូលរួមរៀបចំផែនការស្រាវជ្រាវទាក់ទងទៅនឹងបច្ចេកទេសប្រមូលផលទឹកជ័រជាមួយជំនាញការ CIRAD។

### ❖ កិច្ចសហប្រតិបត្តិការជាមួយ CATAS

កិច្ចសហប្រតិបត្តិការរវាង ***វ.ស.ក.ក*** និងបណ្ឌិតសភា វិទ្យាសាស្ត្រកសិកម្មត្រូពិកចិន(Chinese Academy of Tropical Agricultural Sciences-CATAS) ត្រូវបានរៀបចំឡើង ដោយបានចុះអនុស្សរណៈនៃការយោគយល់នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ នៅទីក្រុង កូឡុមបូ ប្រទេស ស្រីលង្កា។ ក្នុងទិសដៅបង្កើននូវទំនាក់ទំនង និងសកម្មភាពស្រាវជ្រាវអំពីដំណាំកៅស៊ូ។ បន្ទាប់មក ***វ.ស.ក.ក*** និង CATAS បានចុះអនុស្សរណៈនៃការយោគយល់បំពេញបន្ថែមចំនួនបីលើកគឺនៅឆ្នាំ២០១៨មួយលើក ឆ្នាំ២០១៩មួយលើក និងឆ្នាំ២០២០មួយលើក ដើម្បីបន្តសុពលភាពនៃកិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវរួមគ្នា។ នៅឆ្នាំ២០២០នេះ ***វ.ស.ក.ក*** **បាន**ចូលរួមពិភាក្សាជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូនៃបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS) ក្នុងគោលបំណងដើម្បីកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវកៅស៊ូរួមគ្នា។ ក្រុមការងារ CATAS និងក្រុមការងារ CRRI ក៏បានឯកភាពរួមគ្នាសិក្សាអង្កេតអំពី ការប្រើប្រាស់ក្លូនកៅស៊ូក្នុងការដាំដុះ ការប្រើប្រាស់ជីលើដំណាំកៅស៊ូ និងការចៀរប្រមូលផលកៅស៊ូនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ និងចម្ការកៅស៊ូគ្រួសារនៅក្នុងខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី កំពង់ធំ ព្រះវិហារ និងខេត្តសៀមរាប។

ជាមួយគ្នានេះដែរនៅឆ្នាំ២០២០នេះ ***វ.ស.ក.ក*** បាន ចូលរួមជាមួយអង្គការ WWF និងអគ្គនាយកដ្ឋានកៅស៊ូ រៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការប្រមូលផលទឹកជ័រ និងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការប្រមូលផលទឹកជ័ររបស់កៅស៊ូគ្រួសារ នៅខេត្តមណ្ឌលគិរី។

## ៣.២. លទ្ធផលតាមផ្នែក

### ៣.២.១. ការិយាល័យបង្កាត់ពូជ

សកម្មភាពការងារដែលបានអនុវត្តរួមមាន៖

- ស្រង់ទិន្នន័យជ័រកៅស៊ូចម្ការពិសោធន៍ក្នុងនិងក្រៅស្ថានីយសរុបបានចំនួន១៧ចម្ការពិសោធន៍
- ថែទាំច្បារពូជកៅស៊ូទំហំ ៨,៦០ ហិកតាសម្រាប់បំរើដល់ការពិសោធន៍ស្រាវជ្រាវ
- រៀបចំទីតាំង និងស្រង់ទិន្នន័យជំងឺ *Oidium* នៃចម្ការពិសោធន៍ក្លូនក្នុងនិងក្រៅស្ថានីយបានចំនួន១៥៖ *IRAA01,IRAA02, IRAA03, IRAA04,IRAA05, IRAA06, IRAA07, IRAA08, IRAA09, IRAA10, MKAA01, KRAA01, KRAA02, KRAA04 KRAA05*
- វាស់ទំហំដើមកៅស៊ូបានចំនួន១០ ចម្ការពិសោធន៍៖ *IRAA05, IRAA06, IRAA07, IRAA08, IRAA09, IRAA10 ,IRAA11, IRAA12, SSCT01, និង GSET2*
- សិក្សាមាឌឈើរបស់ក្លូននីមួយៗនៃចម្ការពិសោធន៍ក្លូនបានចំនួន០៧៖ *CHAA01, CHAA02, IRAA01, IRAA02, IRAA03, IRAA04 និង IRAA05*
- ចុះត្រួតពិនិត្យទីតាំងដើម្បីរៀបចំច្បារពូជដល់កសិករ នៅឃុំកំពាន់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំបានចំនួន ០២គ្រួសារ
- អង្កេតការជ្រុះស្លឹក និងចេញផ្ការនៅច្បារបង្កាត់ពូជលើក្លូនកៅស៊ូចំនួន១៦
- មន្ត្រីការិយាល័យមួយរូបបានទៅបង្រៀននៅសាលាជាតិកសិកម្មកំពង់ចាម
- ទទួលនិស្សិតសកលវិទ្យាល័យភូមិន្ទកសិកម្មដើម្បីសរសេរសារណាបទបបញ្ចប់ការសិក្សាថ្នាក់ បរិញ្ញាបត្រ បានចំនួន០២នាក់
- ដាំកូនកៅស៊ូបំបៅរួចដែលទទួលបានមកពីក្រុមហ៊ុន SOCFIN-KCD និង CATAS នៅក្នុងច្បារពូជ Collectionសរុបបានចំនួន ១៧ក្លូន
- រៀបចំ Test ចៀរជ័រពិសោធន៍នៅចម្ការ GSET02
- ចុះអង្កេតពីការប្រើប្រាស់ក្លូនកៅស៊ូនៅខេត្តមណ្ឌលគិរី ក្រចេះ និងខេត្តកំពង់ធំ
- សហការជាមួយការិយាល័យសរីរវិទ្យានិងអាជីវកម្មក្នុងការចុះយកសំណាកទឹកជ័រក្នុងចម្ការពិសោធន៍ក្លូន ដើម្បីវិភាគ LD សរុបបានចំនួន ១៣ចម្ការពិសោធន៍
- ចុះផ្សព្វផ្សាយបច្ចេកទេសកៅស៊ូដល់កសិករកៅស៊ូគ្រួសារនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ
- សហការជាមួយអង្គការ WWF-កម្ពុជា ក្នុងការរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការយក ផលទឹកជ័រនិងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការយកផលទឹកជ័ររបស់កៅស៊ូគ្រួសារនៅខេត្ត មណ្ឌលគិរី សរុបបានចំនួនប្រាំបួន(០៩)ចម្ការបង្ហាញ ។



សកម្មភាពរបស់មន្ត្រីនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ចុះប្រមូលសំណាក់ដើម្បីធ្វើតេស្ត LD

# សកម្មភាពការងារមួយចំនួនរបស់ការិយាល័យបង្កាត់ពូជ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា



សកម្មភាពវិភាគសរីរសាស្ត្រទឹកជ័រ (LD) Sucrose, Pi, R-SH



សកម្មភាពនៃការចុះអង្កេតអំពីការប្រើប្រាស់ក្លូនកៅស៊ូនៅខេត្ត មណ្ឌលគិរី ក្រចេះ កំពង់ធំ



សកម្មភាពនៃការចុះជ្រើសរើសចម្ការកៅស៊ូគ្រួសារដើម្បីរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រនិងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការយកផលទឹកជ័ររបស់កៅស៊ូគ្រួសារនៅខេត្តមណ្ឌលគិរី

### ៣.២.២. ការិយាល័យដាំដុះ និងការពារ

សកម្មភាពការងារដែលបានអនុវត្តរួមមាន៖

- តាមដាន ស្រង់និងបញ្ចូលទិន្នន័យចម្ការពិសោធន៍លើផ្ទៃដី៦៨.៦០ហិកតា
- ការស្រាវជ្រាវប្រើប្រាស់ជី និងបរិមាណសមាសធាតុ N.P.K ទៅលើការលូតលាស់ ហើយនិងទិន្នផលជ័រ ដែលទទួលបានពីការដាក់ជីលើចម្ការពិសោធន៍សរុបចំនួន០៦
- រៀបចំថ្នាលបណ្ដុះកូនកៅស៊ូឆ្នាំ២០២០លើផ្ទៃដី ០.៣៥ហិកតា
- អនុវត្តការងារបំប៉ៅកូនកៅស៊ូសម្រាប់ដាំដុះឆ្នាំ ២០២០និងដាំជួសកៅស៊ូដាំឆ្នាំ២០១៩
- អនុវត្តការថែទាំដំណាំគ្របដីចំនួន៣ប្រភេទ(*Stylosanthes guianesis, Mucuna aterrinum, Puraria phaseoloides*)
- ដាក់ជីបំប៉នលើកូនកៅស៊ូមិនទាន់ផ្ដល់ផលចំនួន២លើកលើផ្ទៃដី៦៩ហិកតានិងចម្ការជីលើកៅស៊ូផ្ដល់ផលចំនួន៤ចម្ការ
- ត្រួតពិនិត្យការបើកមុខចៀរឡើងវិញគ្រប់ចម្ការពិសោធន៍លើផ្ទៃដី៥២.៣០ហិចតា
- ថែទាំគ្រប់ចម្ការពិសោធន៍ ព្រមទាំងបាញ់ថ្នាំការពារនិងព្យាបាលជំងឺផ្កាកុលាបនៅតាមប្រគៀបមែកកៅស៊ូចាប់ពីអាយុ៣-១០ឆ្នាំបានចំនួន២លើកលើផ្ទៃដី២១២ហិកតា
- អនុវត្តការងារថែទាំដំណាំចន្លោះរងចំនួន៥ប្រភេទ ស្វាយ ខ្នុរ ម្នាស់ ចេក ស្វាយចន្ទី
- រៀបចំប្រព័ន្ធស្រោចស្រពឡើងវិញ និងស្រោចជាប្រចាំលើចម្ការពិសោធន៍ឥទ្ធិពលនៃការស្រោចស្រពលើការលូតលាស់និងទិន្នផលកៅស៊ូលើផ្ទៃដី ៦,២៥ហិកតា
- ត្រួតពិនិត្យនិងថែទាំឧបករណ៍មន្ទីរពិសោធន៍គីមីកសិកម្ម ដី និងស្លឹក
- ធ្វើតេស្តម៉ាស៊ីនវិភាគជាប្រចាំ អនុវត្តការប្រើប្រាស់ម៉ាស៊ីន Pure Water និង Atomic Absorption Spectrometer និងSUV Spectrometer
- ទទួលនិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម ជំនាញវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ នៃវិទ្យាស្ថានជាតិកសិកម្មព្រែកលាប ចំនួន១រូប និងនិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម ជំនាញដំណាំកៅស៊ូ សាកលវិទ្យាល័យភូមិន្ទកសិកម្មឆ្នាំទី៤ ចំនួន១រូប សរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនៅស្ថានីយអនុវត្ត ខេត្តត្បូងឃ្មុំ
- ទទួលមន្ត្រីពីររូប នៃអគ្គនាយកដ្ឋានកៅស៊ូ ចុះសិក្សាស្វែងយល់ និងដកស្រង់បទពិសោធន៍ស្ដីពីការធ្វើពិពិធកម្មលើដំណាំកៅស៊ូ
- បង្រៀននិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម ជំនាញដំណាំកៅស៊ូ ឆ្នាំទី៣ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាមលើមុខវិជ្ជាដីនិងបច្ចេកទេសដាំដុះដំណាំកៅស៊ូ

### ❖ ចម្ការពិសោធន៏អំពីការធ្វើពិពិធកម្មដំណាំចន្លោះរងកៅស៊ូ

**វ.ស.ក.ក** បានរៀបចម្ការពិសោធន៍ចំនួនពីរគឺ (១)ឥទ្ធិពលនៃដំណាំចន្លោះរងលើការលូតលាស់និងទិន្នផលកៅស៊ូ ក្នុងគោលបំណង វាយតម្លៃឥទ្ធិពលនៃដំណាំចន្លោះរងលើការលូតលាស់ និងទិន្នផលកៅស៊ូ ហើយនិងប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំចន្លោះរងកៅស៊ូ (២)ឥទ្ធិពល និងផលប៉ះពាល់នៃដំណាំគ្របដី និងការប្រើប្រាស់ជីទៅលើការលូតលាស់និងទិន្នផលកៅស៊ូ ហើយនិងការបង្កើតជីវម៉ាស់គ្រប់គ្រងជីជាតិដី។

### ❖ បន្តការតាមដានចម្ការពិសោធន៍

ការតាមដាន និងស្រង់ទិន្នន័យចម្ការពិសោធន៍ត្រូវបានអនុវត្តជាប្រចាំ ក្រោយពីការដាំដុះចម្ការពិសោធន៍រួច។ ការតាមដានស្រង់ទិន្នន័យចម្ការពិសោធន៍ ត្រូវប្រើប្រាស់ពេលវេលាយូរចាប់ពី០៥-២៥ឆ្នាំ ទៅតាមប្រភេទនៃការពិសោធន៍។



សកម្មភាពដាក់ជីបំប៉នលើដំណាំកៅស៊ូក្នុងចម្ការពិសោធន៍នៅស្ថានីយអនុវត្ត ស្ថិតនៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

សកម្មភាពដែលបានអនុវត្តមានដូចខាងក្រោមៈ

- ការធ្វើស្ថិតិចំនួនដើមដាំរស់ និងងាប់
- ការដាំជួសកូនកៅស៊ូដែលងាប់
- ការវាស់វែងទំហំដើមតាមដានការលូតលាស់ត្រូវបានអនុវត្តន៍គ្រប់ដើម នៃការពិសោធន៍ជារៀងរាល់ឆ្នាំម្តង ឬពីរដងទៅតាមពិធីសារពិសោធន៍ដែលបានតម្រូវ
- ការស្រង់ទិន្នន័យទិន្នផល
- ការវិភាគទិន្នន័យ
- ការរៀបចំរបាយការណ៍លទ្ធផលនៃការពិសោធន៍។

# សកម្មភាពការងារមួយចំនួនរបស់ការិយាល័យដាំដុះ និងការពារ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា






សកម្មភាពថែទាំដំណាំចន្លោះរងនិងដំណាំគ្របដី



សកម្មភាពបំបៅកូនកៅស៊ូ



សកម្មភាពនៅថ្នាលបណ្ដុះកូនកៅស៊ូ




សកម្មភាពប្រមូលទិន្នន័យចម្ការពិសោធន៍

### ៣.២.៣. ការិយាល័យសរីរវិទ្យា និងអាជីវកម្ម

សកម្មភាពការងារ និងលទ្ធផលការងារចម្ការពិសោធន៍ដែលបានអនុវត្តរួមមានៈ

- ស្រង់ទិន្នន័យទឹកជ័រគ្រប់ចម្ការពិសោធន៍នៅក្នុងស្ថានីយចំនួន១៣ និងក្រៅស្ថានីយ ចំនួន០១
- ត្រួតពិនិត្យការចៀរជ័រនិងការសាប្រមូលផលទឹកជ័រតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍
- វាស់ទំហំដើមកៅស៊ូតាមដានការលូតលាស់ចម្ការពិសោធន៍នៅក្នុងស្ថានីយបានចំនួន៧ចម្ការ (IRAE06, IRAE07, IRAE08, IRAE16, IRAE17, IRAE18) និងក្រៅស្ថានីយចំនួន០១ចម្ការ (KRAE03)
- ស្រង់ទិន្នន័យដើមចៀរនិងស្ងួតមុខចៀរ (TPD) បានចំនួន១៤ចម្ការពិសោធន៍
- ចុះត្រួតពិនិត្យសម្ភារអាជីវកម្មចម្ការពិសោធន៍និងការអូសក្រិតមុខចៀរជ័រថ្មីគ្រប់ចម្ការពិសោធន៍
- រៀបចំលាយថ្នាំរំញោច Ethephon តាមកំហាប់ខុសៗគ្នា ដើម្បីលាបរំញោចតាមពិធីសាពិសោធន៍
- ត្រួតពិនិត្យការលាបថ្នាំរំញោច Ethephon គ្រប់ចម្ការពិសោធន៍
- សម្អាតស្មៅនិងដាក់ជីចម្ការពិសោធន៍បង្កើនទិន្នផលជ័រកៅស៊ូដោយការប្រើជី ថ្នាំរំញោច និងការចៀរជ័រដោយម៉ាស៊ីន
- ត្រួតពិនិត្យនិងថែទាំសម្ភារ ឧបករណ៍ និងសារធាតុគីមីនៅក្នុងមន្ទីរពិសោធន៍ជីវគីមី និងសរីរវិទ្យា
- ផ្ទៀងផ្ទាត់ (Calibrate) ឧបករណ៍ ជញ្ជីងអេឡិចត្រូនិច ពីប៉េតអូតូម៉ាទិច និង pH ម៉ែត្រ




សកម្មភាពវាស់ទំហំដើមកៅស៊ូចម្ការពិសោធន៍

## សកម្មភាពការងារមួយចំនួនរបស់ការិយាល័យសរីរវិទ្យា និងអាជីវកម្ម នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា





ការណែនាំបច្ចេកទេសចៀរជ័រកៅស៊ូដល់យុវជនសសយក ខេត្តត្បូងឃ្មុំ



ការបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូដល់យុវជនសសយក ខេត្តត្បូងឃ្មុំ



ការណែនាំបច្ចេកទេសចៀរជ័រកៅស៊ូដល់កសិករកៅស៊ូគ្រួសារខេត្តមណ្ឌលគិរី



ការយកសំណាកទឹកជ័រដើម្បីវិភាគសរីរទឹកជ័រ ( LD )



ការវិភាគសរីរទឹកជ័រ( LD )

### ៣.២.៤. មន្ទីរពិសោធន៍ជាតិយថាប្រភេទ

មន្ទីរពិសោធន៍ជាតិយថាប្រភេទគឺជាផ្នែកដ៏សំខាន់មួយរបស់ *វ.ស.ក.ក* និងជាមន្ទីរពិសោធន៍ជាតិដែលមានតួនាទីនៅក្នុងការពង្រឹងគុណភាពផលិតកម្មកៅស៊ូធម្មជាតិកម្ពុជា។ សកម្មភាពការងាររបស់មន្ទីរពិសោធន៍ក្នុងឆ្នាំ ២០២០ រួមមាន៖

- បានធ្វើតេស្តជូនរោងចក្រកៅស៊ូសន្លឹករបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ចំនួន៩ដង
- បានធ្វើតេស្ត និងបានចេញលទ្ធផលតេស្តជូនក្រុមហ៊ុន សុកហ៊ួន កាសេដេ ខូ, អិលធីឌី បានចំនួន៦០ សំណាក
- ទទួលនិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន១រូប ដើម្បីសរសេរសារណាបទបញ្ចប់កាសិក្សា លើប្រធានបទ"លក្ខណៈរូបរបស់កៅស៊ូធម្មជាតិកែច្នៃចេញពីជ័រកកដែល ត្រូវបានបង្កកដោយ "អាលុយមីញ៉ូមប៉ូតាស្យូមស៊ុលផាត ដូដេកាអ៊ីដ្រាតេ" [$KAl(SO_4)_2.12H_2O$]"
- ផ្សព្វផ្សាយសារាចរណែនាំស្តីពី ការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ បានចំនួន១០រោងចក្រ
- បានជូនដំណឹង ស្តីពី "សំណើសុំចូលរួមធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក(Parallel Tests) សម្រាប់ឆ្នាំ២០២០" ជូនដល់បណ្តាក្រុមហ៊ុន រោងចក្របានចំនួន១១ និងមន្ទីរពិសោធន៍មូលដ្ឋានចំនួន៥ ដែលបានចុះបញ្ជិកាជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- បណ្តុះបណ្តាលការអនុវត្តការងារមន្ទីរពិសោធន៍ដល់មន្ត្រីកិច្ចសន្យា
- ទទួលនិស្សិតពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាចំនួន២រូប ដែលបានយកសំណាកមកវិភាគលើឧបករណ៍តង់ស្យូម៉ែត្រ ដើម្បីសរសេរសារណាបទ លើការសិក្សាពីលក្ខណៈរូប គីមី និងមេកានិចនៃល្បាយកៅស៊ូជាមួយជីតជ្ជ និងម្សៅកាល់ស្យូមកាបូណាតសម្រាប់ផលិតផលពូក។



កម្រងរូបភាពសិក្ខាកាមនៃអង្គសិក្ខាសាលាស្តីពី «*ការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូនិងកៅស៊ូគ្រួសារ*» ចុះទស្សនកិច្ចមន្ទីរពិសោធន៍នៃ វ.ស.ក.ក.នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ត្រួតពិនិត្យសម្ភារ និងឧបករណ៍មន្ទីរពិសោធន៍ជាតិយថាប្រភេទ
- មន្ទីរពិសោធន៍ជាតិយថាប្រភេទ បានចូលរួមធ្វើបទបង្ហាញក្នុងអង្គសក្ខាសាលាស្តីពី «*ការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូនិងកៅស៊ូគ្រួសារ*» ចំនួន៣បទបង្ហាញ គឺ:
  ១. បច្ចេកទេសគន្លឹះកែច្នៃកៅស៊ូ TSR និងRSS
  ២.ផលប្រយោជន៍ និងនីតិវិធីក្នុងការបញ្ជិកាពេងចក្រ មន្ទីរពិសោធន៍មូលដ្ឋានដើម្បីទទួលស្គាល់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
  ៣. លទ្ធផលបឋមអំពីការប្រើសាជូរខៀវបង្កកទឹកជ័រ
- រៀបចំឯកសារដើម្បីស្នើសុំស្តង់ដា ISO/IEC 17025: 2017
- បានធ្វើតេស្តសរុបចំនួន៣០២សំណាក(តេស្តប្រៀបធៀបក្នុងស្រុក តេស្តសិក្សាស្រាវជ្រាវពីគុណភាព)
- បានចុះពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូដែលបានស្នើសុំចុះបញ្ជិកា និងចុះបញ្ជិកាជាថ្មី បានចំនួន៤រោងចក្រ និងមន្ទីរពិសោធន៍ចំនួន១
- ការបញ្ចូលទិន្នន័យ និងវិភាគលទ្ធផលតេស្ត
- រៀបចំផែនការនិងសកម្មភាពការងាររបស់មន្ទីរពិសោធន៍ជាតិយថាប្រភេទតាមខែនីមួយៗ




សកម្មភាពការចុះផ្សព្វផ្សាយសារាចណែនាំ ស្តីពី ការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូកម្ពុជា



សកម្មភាពរុញដាក់ជ័រចូលក្នុងឡសំងួត



រូបភាពការយកជ័រចេញពីឡសំងួត

# សកម្មភាពការងារប្រចាំរបស់ មន្ទីពិសោធន៍ជាតិយថាប្រភេទ នៃវិទ្យាស្ថាន ស្រាវជ្រាវកៅស៊ូកម្ពុជា



សកម្មភាពការធ្វើតេស្តភាគរយអាសូត



សកម្មភាពការធ្វើតេស្តសន្ទស្សន៍ពណ៌



សកម្មភាព នៃការធ្វើតេស្តអសុទ្ធភាព



សកម្មភាពការធ្វើតេស្តបំលាស់រូបដើម និងរក្សាបំលាស់រូប



សកម្មភាព នៃការដុត ដើម្បីតេស្តវិភាគផេះ



សកម្មភាពការធ្វើតេស្តរកភាគរយសារធាតុហើរ

### ៣.២.៥ ស្ថានីយអនុវត្ត

- ចាត់ចែងកម្លាំងដាំដុះ កម្លាំងចៀរជ័រ និងការប្រមូលផលកៅស៊ូនៅក្នុងស្ថានីយ៍
- ថែទាំកៅស៊ូចៀរជ័រ (កាប់ព្រៃសម្អាត លាបថ្នាំប៉េត្រូឡាតូមលើដើមកៅស៊ូ...)
- ត្រួតពិនិត្យ ថែទាំ ជួសជុលគ្រឿងចក្រ និងឧបករណ៍ប្រើប្រាស់នៅក្នុងស្ថានីយ
- ត្រួតពិនិត្យការងារកែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រ
- ផ្គត់ផ្គង់អង្ករ ទឹក អគ្គីសនី និងបៀវត្សជូនកម្មករ
- ធ្វើអនាម័យសម្អាតទីធ្លាបរិវេណកន្លែងធ្វើការ កន្លែងស្នាក់នៅក្នុងស្ថានីយ៍



សកម្មភាពលាបថ្នាំរំញោច និងការចៀរជ័រកៅស៊ូ




រូបភាពនៃការរៀបចំប្រព័ន្ធស្រោចស្រពថ្មីនៅស្ថានីយ៍អនុវត្តន៍

### ៣.៣ ការអនុវត្តចរិកាកម្មវិធី

ក្នុងឆ្នាំ២០២០ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាបានខិតខំយកចិត្តទុកដាក់បំពេញការងារតាមកម្មវិធីទី១ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច នៃអនុកម្មវិធីទី១.៦ លើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ ដែលមានចង្កោមសកម្មភាពចំនួន០៣គឺ៖ ១.៦.១៖ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ និងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូដើម្បីបង្កើនផលិតភាពកៅស៊ូ ១.៦.២៖ ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ១.៦.៣៖ទទួលធ្វើសវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យស្គាល់ជាផ្លូវការនិងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ

៣.៣.១.ចង្កោមសកម្មភាពទី១ ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ និងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូដើម្បីបង្កើនផលិតភាពកៅស៊ូ

ក្នុងគោលបំណងសំខាន់គឺ៖ កសាងទិន្នន័យជាសារវន្ត ដើម្បីរៀបចំជាមគ្គុទ្ទេសនិងផ្សព្វផ្សាយដល់អ្នកដាំកៅស៊ូ សំដៅដល់ការបង្កើនផលចំណូលដល់អ្នកដាំកៅស៊ូ ហើយនិងការលើកស្ទួយសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។ ដើម្បី **វ.ស.ក.ក** សម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម៖

- ការបង្កើត ការគ្រប់គ្រង និងស្រង់ទិន្នន័យចម្ការពិសោធន៍
- ការបង្កាត់ ការធ្វើជម្រើស និងអភិវឌ្ឍក្លូនកៅស៊ូ ការគ្រប់គ្រងក្លូនកៅស៊ូ ការគ្រប់គ្រងច្បារពូជ និងអភិវឌ្ឍរុក្ខសម្ភារកៅស៊ូ
- ការរៀបចំអនុសាសន៍ក្លូនកៅស៊ូ
- ការវិភាគសរីរទឹកជ័រ
- ការផ្លាស់ប្តូរក្លូនជាមួយបណ្តាសមាជិក IRRDB ក្នុងការអភិវឌ្ឍន៍ក្លូននិងធនធានសេនេទិចកៅស៊ូ
- ការធ្វើពិពិធកម្មប្រភេទដំណាំចន្លោះរង ដោយយកដំណាំកៅស៊ូជាមូលដ្ឋាន។

៣.៣.២. ចង្កោមសកម្មភាពទី២ ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិក្នុងគោលបំណងសំខាន់គឺ៖ សំដៅធ្វើប្រសើរឡើងនូវខ្សែចង្វាក់តម្លៃកៅស៊ូកម្ពុជា និងកិត្យានុភាពផលិតផលកៅស៊ូកម្ពុជាលើទីផ្សារអន្តរជាតិ ដើម្បីបង្កើននូវតម្លៃបន្ថែម ជំរុញនូវកំណើនសេដ្ឋកិច្ចសង្គមជាតិ និងនិរន្តរភាពផលិតកម្មកៅស៊ូ។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម៖

- ការពង្រឹងមូលដ្ឋានបច្ចេកទេសមន្ទីរពិសោធន៍
- ការពង្រឹងមូលដ្ឋានបច្ចេកទេសរោងចក្រកែច្នៃកៅស៊ូ
- ការចុះបញ្ជិការរោងចក្រនិងមន្ទីរពិសោធន៍មូលដ្ឋានសម្រាប់ការទទួលស្គាល់និងសិទ្ធប្រើប្រាស់ ស្លាកសញ្ញា CSR
- ការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ។

៣.៣.៣. ចង្កោមសកម្មភាពទី៣ ទទួលធ្វើសវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យស្គាល់ជាផ្លូវការនិងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ

ក្នុងគោលបំណង អភិបាលកិច្ចល្អក្នុងការងារពិសោធន៍ស្រាវជ្រាវ ការធ្វើសមាហរណកម្មវិស័យស្រាវជ្រាវជាមួយនិងអន្តរជាតិ ការផ្ទេរបច្ចេកវិទ្យានិងបណ្តុះបណ្តាលធនធានមនុស្ស ការកែលម្អ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការទ្រទ្រង់សុខមាលភាពនិងសុវត្ថិភាពពលកម្ម សំដៅបង្កើនប្រសិទ្ធិភាពស្រាវជ្រាវ ដើម្បីរួមចំណែកនិងជំរុញការអភិវឌ្ឍដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពនិងចីរភាព។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម៖

- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ការបណ្តុះបណ្តាលធនធានមនុស្សនិងផ្ទេរបច្ចេកវិទ្យា
- ការចូលរួមដៃគូស្រាវជ្រាវជាមួយភាគីអន្តរជាតិ
- ការផ្តល់សេវាបច្ចេកទេសគាំទ្រ
- ការងារគ្រប់គ្រងរដ្ឋបាល

ដើម្បីធានាដល់ភាពជោគជ័យ លើសកម្មភាពនៃការអនុវត្តគម្រោងដោយផ្ទៀងផ្ទាត់លទ្ធផលដែលសម្រេចបានជាមួយនឹងសូចនាករ ដែលបានកំណត់នៅក្នុងផែនការ ការពិនិត្យ តាមដាន និងវាយតម្លៃគឺនឹងត្រូវធ្វើឡើង។ ការវាយតម្លៃនៃការអនុវត្តនេះត្រូវបានធ្វើឡើងនៅពេលកំពុងអនុវត្តរហូតដល់ការបញ្ចប់នៃគម្រោង ដោយនាយកដ្ឋាន ផែនការនិងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈរបាយការណ៍ប្រចាំខែ របាយការណ៍ត្រីមាស របាយការណ៍ឆមាស របាយការណ៍ប្រចាំឆ្នាំ និងការចុះវាយតម្លៃដោយផ្ទាល់រៀងរាល់ឆ្នាំ។ វ.ស.ក.ក ក៏មានការរៀបចំជាគណៈកម្មការវាយតម្លៃផ្ទៃក្នុងផ្ទាល់ខ្លួនផងដែរ សម្រាប់តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធានាបាននូវភាពច្បាស់លាស់ ហើយនិងភាពជោគជ័យនៃការអនុវត្តគម្រោង។

## ៤.ផ្នែកហេដ្ឋារចនាសម្ព័ន្ធ

- ជួសជុលផ្ទះស្នាក់នៅចំនួន២៥ខ្នង បណ្តាញទឹក និងបណ្តាញភ្លើងរបស់កម្មករក្នុងភូមិ៣២
- ជួសជុលសាលារៀន សាលាសន្សំកុសលនៅក្នុងភូមិ៣២
- ជួសជុលលាបថ្នាំអគារស្នាក់នៅ របស់មន្រ្តីរាជការនៅក្នុងស្ថានីយ
- ជួសជុលផ្លូវក្នុងចម្ការកៅស៊ូពិសោធន៍របស់ *វ.ស.ក.ក.*
- ដាំផ្កានៅមុខអគារការិយាល័យ និងនៅមុខមន្ទីរពិសោធន៍ជាតិយថាប្រភេទក្នុងស្ថានីយ។



ការរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសោភ័ណភាពនៅមុខអគារការិយាល័យ ក្នុងស្ថានីយ៍

## ៥.ទិសដៅការងារឆ្នាំ២០២១ និងសន្និដ្ឋាន

### ៥.១. ទិសដៅការងារឆ្នាំ២០២១

- បង្កើនការយកចិត្តទុកដាក់បន្តការងារស្រាវជ្រាវ
- យកចិត្តទុកដាក់ក្នុងការកសាងធនធានមនុស្ស បំពេញឲ្យធនធានមនុស្សដែលខ្វះខាត
- ពង្រឹងការអនុវត្តគម្រោងផែនការ និងសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១ ឲ្យមានប្រសិទ្ធិភាព
- ខិតខំពង្រឹងភាពជាដៃគូស្រាវជ្រាវជាមួយបណ្ដាសាកលវិទ្យាល័យ ក្រុមហ៊ុន រោងចក្រកែច្នៃ និងអន្តរាគមន៍រាល់សេវាបច្ចេកទេស បែបបទចុះបញ្ជិការោងចក្រ មន្ទីរពិសោធន៍ដើម្បីបានការទទួលស្គាល់ពី វ.ស.ក.ក. ក្នុងការប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា
- បន្តការយកចិត្តទុកដាក់លើការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ និងកៅស៊ូគ្រួសារ
- ពង្រឹងការអនុវត្តលើការបំពេញបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ(C S R )សម្រាប់ការនាំចេញកៅស៊ូកែច្នៃ និងវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ
- ការអនុវត្តកម្មវិធីផ្លាស់ប្ដូរក្លូនពហុភាគីក្នុងរង្វង់ប្រទេសជាសមាជិក IRRDB
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសសមាជិក IRRDB និងអង្គការអន្តរជាតិ ព្រមទាំងភាគីជាតិ ដូចជាបណ្ដាសាកលវិទ្យាល័យ ក្រុមហ៊ុន រោងចក្រកែច្នៃ ហើយនិងអន្តរាគមន៍រាល់សេវាបច្ចេកទេស បែបបទចុះបញ្ជិការោងចក្រ មន្ទីរពិសោធន៍
- ចូលរួមសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យា
- ចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានាក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សលើមុខវិជ្ជាបច្ចេកទេសដាំដុះ ការប្រមូលផលទឹកជ័រ សរីរសាស្ត្រទឹកជ័រ ជំងឺ និងកត្តាចង្រៃលើដំណាំកៅស៊ូ
- ស្នើសុំការទទួលស្គាល់ប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025: 2017
- បន្តចូលរួមជាមួយអង្គការ WWF និងអគ្គនាយកដ្ឋានកៅស៊ូរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ និងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការយកផលទឹកជ័ររបស់កៅស៊ូគ្រួសារនៅខេត្តមណ្ឌលគិរី
- បន្តសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការកៅស៊ូអន្តរជាតិនានា ក្នុងក្របខណ្ឌការងារស្រាវជ្រាវបច្ចេកទេសប្រមូលផលទឹកជ័រ។

### ៥.២. សេចក្ដីសន្និដ្ឋាន

សកម្មភាព និងលទ្ធផលការងារ ដែលវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាសម្រេចបាននេះ ដោយសារមានផែនការការងារច្បាស់លាស់ និងកិច្ចសហការយ៉ាងជិតស្និទ្ធ រវាងមន្ត្រីរាជការ និយោជិតទាំងអស់ ជាមួយថ្នាក់ដឹកនាំ **វ.ស.ក.ក** ក្នុងការអនុវត្តតួនាទីភារកិច្ច និងមានការទទួលខុសត្រូវ ក្នុងបេសកកម្មរបស់ខ្លួននិងផែនការ ដែលបានកំណត់ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ របស់ក្រុមប្រឹក្សាភិបាល ព្រមជាមួយគ្នានោះ ក៏មានការយកចិត្តទុកដាក់ ចង្អុលបង្ហាញ និងការគាំទ្រពីស្ថាប័នជំនាញ ជាអណាព្យាបាលរួមមាន៖ **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** និង **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ក្នុងការជំរុញ ការអភិវឌ្ឍន៍វិស័យកៅស៊ូនៅកម្ពុជា ស្របតាមគោលនយោបាយអភិវឌ្ឍន៍ របស់រាជរដ្ឋាភិបាលកម្ពុជា។

សកម្មភាព និងលទ្ធផលការងារខាងលើនេះ សម្រេចបានដោយមានការចូលរួមពីបណ្ដាដៃគូជាតិ រួមមានប្រតិបត្តិករកៅស៊ូទាំងអស់ដែលបានផ្ដល់ការទុកចិត្ត ចូលរួមនិងគាំទ្រ ជាងនេះទៅទៀតគឺការចូលរួមសហការពីបណ្ដាដៃគូអន្តរជាតិពាក់ព័ន្ធដូចជា៖ CIRAD, AFD, IRRDB, HRPP, CATAS,...។

# ៦. ការប្រជុំ និងសិក្ខាសាលា

## ៦.១. ការប្រជុំ និងសិក្ខាសាលាក្នុងប្រទេស





ការប្រជុំផ្ទៃក្នុងរបស់ថ្នាក់ដឹកនាំនៃ *វ.ស.ក.ក* ក្រោមអធិបតីភាព **លោក លិម ខាន់ទីវ៉ា** នាយក *វ.ស.ក.ក* ដើម្បីពិភាក្សាអំពីវឌ្ឍភាព និងលទ្ធផល នៃការអនុវត្តការងារ ក្នុងខែចាស់ និងលើកទិសដៅសម្រាប់អនុវត្តក្នុងខែបន្ទាប់ ដែលប្រព្រឹត្តទៅរាងរាល់មួយខែម្តង







**ឯកឧត្តម ប៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អញ្ជើញជាអធិបតីភាពដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល *វ.ស.ក.ក* ដើម្បីពិនិត្យវឌ្ឍនភាពការងាររយៈពេល៩ខែ លើកទី៤ អាណត្តិទី៦ នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០

ថ្ងៃពុធ ១២កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០ ថ្នាក់ដឹកនាំវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តការងារឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តម ម៉ាន សុគ្រី** រដ្ឋលេខាធិការតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ក្នុងពិធីនេះដែរ **លោក លិម ខាន់ទីវ៉ា** អតីតនាយករងវិទ្យាស្ថាន បានធ្វើបទបង្ហាញ អំពីជំងឺស្លឹកកៅស៊ូ Pestalotiopsis ដែលជាជំងឺដ៏កាចសាហាវកំពុងរាតត្បាតក្នុងបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិមួយចំនួន បណ្តាលឱ្យបាតបង់ទិន្នផលពី ២៥-៥០%។












ដើម្បីឆ្លើយតបតាមសំណើរបស់សមាគមកសិករអ្នកដាំកៅស៊ូគ្រួសាររីកចម្រើន (តំបន់តំបែរ) នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ លោកនាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានចាត់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចុះផ្តល់ប្រឹក្សាបច្ចេកទេសអំពីការរៀបចំច្បារពូជ និងថ្នាលបណ្តុះកូនកៅស៊ូដល់កសិករចំនួនពីរគ្រួសារ នៅភូមិស្រែកណ្តាល និងភូមិកំពាន់ ឃុំកំពាន់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ













នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ **លោក ហាក់ ម៉ិនឈួន** នាយករងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានដឹកនាំមន្ត្រីជំនាញចុះត្រួតពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃជ័រកៅស៊ូ ដែលមានទីតាំងស្ថិតនៅភូមិថ្មសម្លៀង ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដើម្បីចុះបញ្ជិកា និងផ្តល់សិទ្ធិឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា



សកម្មភាពនៃការបំពេញនូវសំណុំបែបបទដែលពាក់ព័ន្ធ



សកម្មភាពការចុះពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូតានបៀនកំពង់ធំ អភិវឌ្ឍន៍កៅស៊ូ



សកម្មភាពនៃការចុះពិនិត្យរោងចក្រ



ថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំក្រុមហ៊ុន

នៅព្រឹកថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ សិក្ខាកាមជាច្រើនបានធ្វើទស្សនកិច្ចមន្ទីរពិសោធន៍ជាតិយថាប្រភេទ មន្ទីរពិសោធន៍ជីវគីមីនិងសរីរវិទ្យា និងចម្ការពិសោធន៍មួយចំនួនទៀតរបស់ **វ.ស.ក.ក**





កាលពីថ្ងៃទី១៤ ១៥ ខែឧសភា ឆ្នាំ២០២០ នៅស្ថានីយអនុវត្ត នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ស្ថិតនៅភូមិ៣២ ឃុំជីរោទិ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ **លោក ហាក់ ម៉ុនឆួន** នាយករងវិទ្យាស្ថាន និង មន្រ្តីជំនាញមន្ទីរពិសោធន៍ជាតិយថាប្រភេទ បានដឹកនាំនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជំនាញវិទ្យាសាស្រ្តកៅស៊ូចុះសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី ការប្រៀបធៀបលក្ខណៈរូបនៃកៅស៊ូធម្មជាតិកែច្នៃចេញពីជ័រកកដែលត្រូវបង្កកដោយអាស៊ីតស៊ុលផួរិច អាលុយមីញ៉ូមស៊ុលផាតអ៊ីដ្រាតេ និងអាស៊ីតហ្វ័រមិច។ ការស្រាវជ្រាវនេះគឺមានគោលបំណងស្វែងយល់ពីឥទ្ធិពលនៃអាស៊ីតស៊ុលផួរិច និងអាលុយមីញ៉ូមស៊ុលផាតអ៊ីដ្រាតេ លើរចនាសម្ព័ន្ធកៅស៊ូដោយមានការសង្ស័យថាវាធ្វើអោយថយគុណភាពផលិតផលសម្រេច។










ថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា សហការជាមួយដៃគូឯកជន បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី ការផ្ទេរបច្ចេកវិទ្យាកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ និងកៅស៊ូគ្រួសារ នៅសណ្ឋាគារ LBN ASEAN ខេត្តកំពង់ចាម ដោយមានអ្នកចូលរួមចំនួន ១២៤នាក់ ក្នុងនោះមានស្ត្រីចំនួន១៩នាក់។ ផ្ទាំងបង្ហាញចំនួន៤ និងបទបង្ហាញបច្ចេកទេសចំនួន៩ ពាក់ព័ន្ធនឹងសរីរវិទ្យានិងការវិភាគទឹកជ័រ វឌ្ឍនភាពនៃការប្រើប្រាស់ក្លូនកៅស៊ូនៅកម្ពុជា ការប្រើប្រាស់ជីលើកៅស៊ូកំពុងផ្តល់ផល ជំងឺស្លឹកកៅស៊ូ Pestalotiopsis ការបើកមុខចៀរដំបូង បច្ចេកទេសប្រមូលផលទឹកជ័រកៅស៊ូនិងចង្វាក់នៃការលាបថ្នាំរំញោចបង្កើនទិន្នផល បច្ចេកទេសគន្លឹះកែច្នៃកៅស៊ូ TSR និង RSS ផលប្រយោជន៍និងនីតិវិធីក្នុងការចុះបញ្ជីការរោងចក្រ មន្ទីរពិសោធន៍មូលដ្ឋានដើម្បីវាយតម្លៃទទួលស្គាល់ដោយ *វ.ស.ក.ក* និងលទ្ធផលបឋមអំពីការប្រើសាជូរខៀវបង្កកទឹកជ័រ ត្រូវបានបង្ហាញនៅថ្ងៃ៣០ ខែកញ្ញា ឆ្នាំ២០២០។

នៅព្រឹកថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ សិក្ខាកាមជាច្រើនបានធ្វើទស្សនកិច្ចមន្ទីរពិសោធន៍ជាតិយថាប្រភេទ មន្ទីរពិសោធន៍ជីវគីមីនិងសរីរវិទ្យា និងចម្ការពិសោធន៍មួយចំនួនទៀតរបស់ *វ.ស.ក.ក* តាមរយៈសិក្ខាសាលា និងទស្សនកិច្ចសិក្សានេះ សិក្ខាកាមបានទទួលនូវចំណេះដឹងថ្មីៗជាច្រើនសម្រាប់យកទៅអនុវត្តនៅចម្ការកៅស៊ូរបស់ពួកគាត់។ ជាមួយគ្នានេះដែរ ថ្នាក់ដឹកនាំ *វ.ស.ក.ក* បានសំណូមពរឱ្យសិក្ខាកាមទាក់ទងមក *វ.ស.ក.ក* បើសិនពួកគាត់ជួបបញ្ហាបច្ចេកទេសលើដំណាំកៅស៊ូ និងរាយការណ៍ជូន *វ.ស.ក.ក* ឬក៏អគ្គនាយកដ្ឋានកៅស៊ូ ជាបន្ទាន់នៅពេលដែលមានជំងឺប្លែកៗកើតឡើង។






រូបភាពថ្នាក់ដឹកនាំរបស់ *វ.ស.ក.ក* និងសិក្ខាកាម

ទិដ្ឋភាពសមាជិក ចូលរួមនៃសិក្ខាសាលា





ថ្នាក់ដឹកនាំនៃ *វ.ស.ក.ក* ធ្វើបទបង្ហាញអំពីជំងឺកៅស៊ូនៅកម្ពុជា

សិក្ខាកាមជាច្រើនបានធ្វើទស្សនកិច្ចមន្ទីរពិសោធន៍ជាតិយថាប្រភេទ មន្ទីរពិសោធន៍ជីវគីមីនិងសរីរវិទ្យា និងចម្ការពិសោធន៍មួយចំនួនទៀតរបស់ *វ.ស.ក.ក*

ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ **លោក លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ព្រមទាំងមន្ត្រីជំនាញ បានចូលរួមប្រជុំពិភាក្សាជាមួយ ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ សហគមន៍កៅស៊ូគ្រួសារស្រុកមេមត់ និងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ ក្រោមការដឹកនាំកិច្ចប្រជុំដោយ **លោក ឃី តុសល** អគ្គលេខាធិការរង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិភាក្សារកធាតុចូលសម្រាប់បញ្ចូលក្នុងគម្រោង Rainfed agriculture។ បន្ទាប់ពីកិច្ចពិភាក្សាបានបញ្ចប់ ក្រុមការងារបានធ្វើទស្សនកិច្ចច្បារពូជកៅស៊ូនិងចម្ការពិសោធន៍ដែលគាំទ្រដោយគម្រោង AFD ហើយនិងមន្ទីរពិសោធន៍ជាតិយថាប្រភេទ និងចម្ការពិសោធន៍វាយតម្លៃកូនកៅស៊ូស៊ីដលីង។



សកម្មភាពនៃកាប្រជុំពិភាក្សា



កាចុះទស្សនកិច្ចមន្ទីរពិសោធន៍ជាតិយថាប្រភេទ









កាចុះទស្សនកិច្ចច្បារពូជកៅស៊ូ និងចម្ការពិសោធន៍ដែលគាំទ្រដោយគម្រោង AFD នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

នៅថ្ងៃអង្គារ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ លោកនាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានចាត់មន្ត្រីជំនាញចំនួន០២រូប ដើម្បីចូលរួមធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូ ដល់យុវជន សសយក ស្រុកមេមត់ និងកសិករកៅស៊ូគ្រួសារនៅឃុំរំចេក។ ចូលរួមជាអធិបតីក្នុងវគ្គបណ្តុះបណ្តាលនេះមាន **លោក ហេង ពិសិដ្ឋ** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ **លោក តាណា ជេដ្ឋា** ប្រធានការិយាល័យបង្កាត់ពូជនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និង **កញ្ញា ទី លីហ្វាន់** អភិបាលរងស្រុកមេមត់ និងជាអនុប្រធាន សសយក ស្រុកមេមត់។



រូបថតថ្នាក់ដឹកនាំធ្វើជាអធិបតីក្នុងវគ្គបណ្តុះបណ្តាល



ការធ្វើបទបង្ហាញរបស់ថ្នាក់ដឹកនាំ **វ.ស.ក.ក**







រូបភាពអនុស្សាវរីយ៍បថ្នាកដឹកនាំនៃ **វ.ស.ក.ក** ជាមួយយុវជន សសយក



ទិដ្ឋភាពនៃការទស្សកិច្ចនៅចម្ការកៅស៊ូ

## ៧. រូបភាពសកម្មភាពផ្សេងៗទៀត




ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ **លោក លឹម ខានធីវ៉ា** បានទទួលប្រកាសឲ្យចូលកាន់តំណែង ជានាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលបានរៀបចំឡើងនៅទីស្តីការក្រសួង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមអធិបតីរបស់ **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

# សកម្មភាពការថែទាំ និងដាំដុះដំណាំកៅស៊ូ ឆ្នាំ២០២០



ការដាំជួសកូនកៅស៊ូ



ការជំរះវែករងកូនកៅស៊ូ



ការដាក់ជីបំប៉នកូនកៅស៊ូ



សកម្មភាពបាញ់ថ្នាំការពារ និងព្យាលបាលជំងឺ



ច្រកដីនៅថ្នាលបណ្តុះកូនកៅស៊ូ



ការបែងចែកចង្អូរ នៅថ្នាលបណ្តុះកូន

# រូបភាពសកម្មភាពការងាររបស់មន្ត្រី នៅការិយាល័យបង្កាត់ពូជ



ការថែទាំច្បារបង្កាត់ពូជ



ការថែទាំច្បារពូជកៅស៊ូសម្រាប់បម្រើដល់ការពិសោធន៍



ការវាស់មាឌឈើតាមក្លូននីមួយៗ



សកម្មភាពស្រង់ទិន្នន័យជំងឺ *Oidium*



សកម្មភាពចៀរជ័រនៅចម្ការ GSET02



សកម្មភាពប្រមូលទិន្នន័យជ័រពិសោធន៍

# រូបភាពសកម្មភាពការងាររបស់មន្ត្រីការិយាល័យសរីរវិទ្យា និងអាជីវកម្ម



សកម្មភាពវាស់ទំហំដើមតាមដានការលូតលាស់



សកម្មភាពវាស់ជំងឺស្លួតមុខចៀរ



សកម្មភាពវិភាគរកបរិមាណជ័រកៅស៊ូស្ងួត (DRC) តាមឧបករណ៍មេត្រូឡាក់



សកម្មភាពវិភាគសរីរទឹកជ័រ



ការបង្ហាញអំពីរបៀបនៃការយកសំណាកទឹកជ័រ នៅចម្ការពិសោធន៍ខេត្តមណ្ឌលគិរី



សកម្មភាពដាក់ជីព្យាបាលជំងឺស្លួតមុខចៀរ

# រូបភាពសកម្មភាពចុះពិនិត្យនិងវាយតម្លៃរោងចក្របារ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ និងយកសំណាក នៅក្រុមហ៊ុន តានបៀន គៀកវ៉ា និងក្រុមហ៊ុន ស៊ី.អ. ស៊ី.ខេ២ កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ



សកម្មភាពពិនិត្យខ្សែសង្វាក់ផលិតកម្មរោងចក្រកែច្នៃកៅស៊ូបារ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ



សកម្មភាពពិនិត្យឃ្លាំងស្តុកជ័រកកររោងចក្រកែច្នៃកៅស៊ូបារ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ



ការពិនិត្យបំណែកគ្រាប់ជ័រមុនចូលឡចំអិននៅរោងចក្រកែច្នៃកៅស៊ូបារ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ



សកម្មភាពនៃការបំពេញនូវសំណុំបែបបទដែលពាក់ព័ន្ធនឹងការចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូរបស់ក្រុមហ៊ុនបារ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ



ការកាត់យកសំណាករបស់រោងចក្រកែច្នៃកៅស៊ូ នៃក្រុមហ៊ុនគៀកវ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ



ការកាត់យកសំណាករបស់រោងចក្រកែច្នៃកៅស៊ូ នៃក្រុមហ៊ុនតានបៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ

# រូបភាពសកម្មភាពចុះពិនិត្យរោងចក្រកែច្នៃកៅស៊ូ CSR នៃក្រុមហ៊ុនដុង ភូ ក្រចេះអភិវឌ្ឍន៍កៅស៊ូ និង ស្វីហ្វ វ៉ាប់ប៊ើ លីមីធីត ខេត្តរតនគិរី




ការពិនិត្យស្លាកសញ្ញានាំចេញកៅស៊ូកម្ពុជា នៅក្រុមហ៊ុនដុងភូ



សកម្មភាពពិនិត្យម៉ាស៊ីនប្រេសកៅស៊ូនៅ ក្រុមហ៊ុនដុងភូ



សកម្មភាពកាត់ភាគសំណាកកៅស៊ូនៅ ក្រុមហ៊ុនដុងភូ



សកម្មភាពនៃការបំពេញនូវសំណុំបែបបទដែលពាក់ព័ន្ធនឹងការចុះបញ្ជិកាជាថ្មីរបស់ក្រុមហ៊ុនស្វីហ្វ វ៉ាប់ប៊ើ លីមីធីត ខេត្តរតនគិរី



ការពិនិត្យអាងសំអាតជ័រកកនៅក្រុមហ៊ុនស្វីហ្វ វ៉ាប់ប៊ើ



ពិនិត្យគ្រាប់ជ័រមុនបញ្ចូលក្នុងឡសម្ងួត នៅក្រុមហ៊ុន ស្វីហ្វ វ៉ាប់ប៊ើ

# រូបភាពសកម្មភាពចុះពិនិត្យមន្ទីរពិសោធន៍នៃក្រុមហ៊ុនសុកហ្វីន កាសេដេ ខេត្តមណ្ឌលគិរី



សកម្មភាពពិនិត្យការបែងចែកសំណាកពិសោធន៍



សកម្មភាពពិនិត្យម៉ាស៊ីនម៉ូនីវីស្កូស៊ីធី



សកម្មភាពពិភាក្សាពីឧបករណ៍វិភាគអាសូត



សកម្មភាពរៀបចំឧបករណ៍សម្រាប់ទីតត្រេអាសូត



សកម្មភាពពិនឿតការបូមអាស៊ីត



សកម្មភាពរៀបចំការវិភាគអាសូត